មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

ភ្នំពេញ ថ្ងៃទី១៦ មករា ឆ្នាំ២០១២

## ម.ស.ម.ក អំពាវនាវឱ្យកម្ពុជាបង្ហាញពីភាពជាអ្នកដឹកនាំដ៏មោះមុតលើឆាកជាតិ និងអន្តរជាតិ ក្នុងការលើកកម្ពស់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម. ស. ម. ក) គឺជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យមួយដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅក្នុងព្រះរាជាណាចក្រកម្ពុជា (កម្ពុជា) សូមស្វាគមន៍ចំពោះគោលនយោបាយបរទេសដែលរីកចម្រើនរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បី "លើកកម្ពស់ និងការពារ" សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ នៅទូទាំងពិភពលោក ហើយក៏សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ឲ្យបង្ហាញពីភាពជាអ្នកដឹកនាំដ៏មោះមុតលើឆាកជាតិ និងអន្តរជាតិ ក្នុងការលើកកម្ពស់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ។

បន្ទាប់ពីការប្រកាសអនុស្សារណៈដែលចុះហត្ថលេខាដោយលោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា នាថ្ងៃអង្គារ ទី៦ ខែធ្នូ ឆ្នាំ២០១១មក លោកស្រី ហ៊ីឡារី រ៉ូដាំ គ្លីនតុន រដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ក្នុងឱកាសថ្លែងទៅកាន់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងដោយនៅចំពោះមុខអ្នកចូលរួមមកពីពិភពអារ៉ាប់ អាហ្វ្រិក និងបណ្តាប្រទេសជាច្រើនទៀតដែលមិនមានការយកចិត្តទុកដាក់ចំពោះសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា ស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនោះ បានអំពាវនាវដល់ប្រទេសទាំងអស់នៅលើពិភពលោកឲ្យគោរពសិទ្ធិពលរដ្ឋនៃអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ។ គោលដៅស្តីពីសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅលើពិភពលោក ដែលបានបង្ហាញក្នុងអនុស្សារណៈរបស់ប្រធានាធិបតីអាមេរិក គឺមានគោលបំណង (១) ប្រយុទ្ធប្រឆាំងនឹងការដាក់ទោសលើស្ថានភាពនៃអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ (២) ការពារជនភៀសខ្លួន និងអ្នកស្វែងរកសិទ្ធិជ្រកកោនដែលជាអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទងាយរងគ្រោះ (៣) អានុភាពនយោបាយនៃជំនួយបរទេសដើម្បីការពារសិទ្ធិមនុស្ស និងលើកកម្ពស់គោលការណ៍មិនរើសអើង (៤) ធានាការឆ្លើយតបទាន់ពេលវេលា និងមានប្រសិទ្ធិភាពរបស់សហរដ្ឋអាមេរិក ក្នុងការប្រយុទ្ធប្រឆាំងនឹងការរំលោភសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅបរទេស និង(៥) ជម្រុញអង្គការអន្តរជាតិនានាក្នុងប្រយុទ្ធប្រឆាំងនឹងការរើសអើងលើអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ។

ទោះបីជាថ្មីៗនេះ នៅប្រទេសកម្ពុជាមានកម្រិតប្រសើរឡើងមួយចំនួនទាក់ទងទៅនឹងការយល់ដឹង និងការអធ្យាស្រ័យមួយចំនួនពីសង្គម ប៉ុន្តែអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ នៅតែប្រឈមនឹងបញ្ហាជាច្រើន ជាពិសេសការរើសអើងដែលពួកគាត់ជួបប្រទះពីគ្រប់មជដ្ឋាន ដូចជាមជដ្ឋានគ្រួសារ និយោជិត និងមន្ទីរមណ្ឌល រមមានមន្ទីរនគរបាលជាដើម។

ម.ស.ម.ក សូមធ្វើការគូសបញ្ជាក់អំពីគំនិតផ្តួចផ្តើមនាពេលថ្មីៗនេះ ដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកនៃរដ្ឋបាលលោកប្រធានាធិបតី បារ៉ាក់ អូបាម៉ា ក្នុងការលើកកម្ពស់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ។ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាផ្ទាល់ សូមអបអរសាទរ ចំពោះសេចក្តីប្រកាសជាសាធារណៈរបស់សហរដ្ឋអាមេរិក កាលពីថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១១ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រលាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅក្រៅប្រទេសតាមរយៈការប្រើប្រាស់ជំនួយបរទេស និងនយោបាយការទូត ដើម្បីផ្តួចផ្តើមធ្វើកំណែទម្រង់។ ជារឿយៗ សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទត្រូវបានគេ មើលរំលង ឬត្រូវបានគេរំលោភបំពាន។ ទោះជាយ៉ាងណាក៏ដោយ គោលជំហររបស់សហរដ្ឋអាមេរិកតំណាងឱ្យជំហានរីកចំរើនដ៏ពិតប្រាកដមួយឆ្ពោះទៅរកការការពារសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅទូទាំងពិភពលោក។ ជាប្រការមួយដែលគួរឱ្យកោតសរសើរ ចំពោះគំនិតផ្តួចផ្តើមទាំងអស់នេះ ដែលមានបំណងផ្តល់ជំនួយអភិវឌ្ឍន៍ ដល់ប្រទេសផ្សេងៗជាច្រើន ដូចជាៈ ប្រទេសអ៊ុយហ្គង់ដា ដែលជាប្រទេសមួយមានកេរ្តិ៍ឈ្មោះមិនល្អ ដោយសារភាពមិនចេះអធ្យាស្រ័យឲ្យអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ –ប្រទេសហុងឌូរ៉ាស ម៉ាឡាវី និងប្រទេសដទៃទៀត។ ទស្សនៈយល់ឃើញរបស់លោកប្រធានាធិបតី អូប៉ាម៉ា គឺជាការរីកចំរើនថ្មីមួយដែលកំពុងតែធ្វើឲ្យមានការយល់ដឹងកាន់តែទូលំទូលាយអំពីសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ហើយក៏ផ្តល់ដល់កម្ពុជានូវ មគ្គុទេសន៍ និងការគាំទ្រផងដែរ។

រាជរដ្ឋាភិបាលកម្ពុជា អាចយកគំរូតាមគំនិតផ្តួចផ្តើមរបស់សហរដ្ឋអាមេរិក ហើយជួយអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទតាមវិធីបីយ៉ាងដូចជាៈ (១) កម្ពុជាអាចផ្សព្វផ្សាយពាក្យសំដីរបស់លោកប្រធានាធិបតិ អូបាម៉ា និងនិយាយជាចំហ ដើម្បីជាប្រយោជន៍ដល់សិទ្ធិនៃអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ នឹងប្រកាសប្រឆាំងនឹងការរើស–អើង។ (២) ផ្តួចផ្តើមឱ្យមានការអនុម័តច្បាប់ប្រឆាំងនឹងការរើសអើងនៅកម្ពុជាដែលបច្ចុប្បន្ននេះនៅមានការខ្វះខាតនៅឡើយ។ (៣) កម្ពុជាអាចប្រើតួនាទីរបស់ខ្លួនក្នុងនាមជាប្រធានសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ដើម្បីជម្រុញឱ្យមានកំណែទម្រង់ក្នុងតំបន់ទាំងមូល តាមរយៈការប្រមូលមតិគ្នាដើម្បីដាក់បញ្ចូលបទបញ្ញត្តិនានា ដែលការពារសិទ្ធិអ្នកដែលស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ទៅក្នុងសេចក្តីព្រាងនៃសេចក្តីប្រកាសស្តីពីសិទ្ធិមនុស្សអាស៊ានដែលបច្ចុប្បន្ននេះកំពុងតែត្រូវបានពិភាក្សា និងធ្វើបញ្ចប់។

ជាមួយនឹងភាពជាអ្នកដឹកនាំដ៏មោះមុតលើឆាកជាតិ និងអន្តរជាតិ នៃរាជរដ្ឋាភិបាលកម្ពុជា ម.ស.ម.ក មានការជឿជាក់យ៉ាងមុតមាំថា ស្ថានភាពនៅក្នុងប្រទេសកម្ពុជានឹងបន្តធ្វើឱ្យកាន់តែមានភាពប្រសើរឡើងចំពោះអ្នកស្រលាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ហើយពួកគាត់អាចប្រើប្រាស់សិទ្ធិរបស់ពួកគាត់ដោយពេញលេញ ហើយថាកម្ពុជាអាចបង្កើតកេរ្តិ៍ដំណែលដ៏ល្អមួយនៅក្នុងតំបន់

–ចប់–

**សម្រាប់ព័ត៌មានបន្ថែមទំនាក់ទំនង លោក ហែម សុខលី អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នៃមជ្ឍមណ្ឌលសិទ្ធិមនុស្សកម្ពុជាតាមរយៈអ៊ីម៉ែលៈ** soklyhem@cchrcambodia.org
**ទូរស័ព្ទ: 092 805 808**